# សាររបស់ឯកអគ្គរាជទូតថ្មីនៃប្រទេសជប៉ុន
# ជូនចំពោះបងប្អូនប្រជាពលរដ្ឋកម្ពុជា

សូមគោរពបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ជាទីស្រលាញ់រាប់អាន!

ខ្ញុំសូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ថា ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាសារជាថ្មីម្តងទៀត ក្នុងឋានៈជាឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមរំលឹកឡើងវិញនូវការចាប់ផ្តើមនៃទំនាក់ទំនងដ៏មាននិស្ស័យរបស់ខ្ញុំជាមួយកម្ពុជា គឺនៅឆ្នាំ ១៩៦៧ ខ្ញុំបានមកដល់ទីក្រុងភ្នំពេញ ដើម្បីសិក្សាភាសាខ្មែរ ។ នៅពេលនោះ វប្បធម៌ដ៏ភ្លឺស្វាង និង ប្រវត្តិសាស្ត្រដ៏រុងរឿងនៃប្រទេសកម្ពុជាបានទាក់ទាញអារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង ហើយធ្វើឱ្យខ្ញុំចង់ស្វែងយល់កាន់តែស៊ីជម្រៅថែមទៀត។

ចាប់តាំងពីពេលនោះមក ខ្ញុំតែងតែយកចិត្តទុកដាក់ដល់ទំនាក់ទំនងជាមួយកម្ពុជា ក៏ដូចជាមានឱកាសជួបសំណេះសំណាល ហើយមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយបងប្អូនប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ ទោះបីជាខ្ញុំនៅទីណាក៏ដោយ ដូចជានៅឯស្ថានទូតជប៉ុនប្រចាំកម្ពុជា នៅឯក្រសួងការបរទេសជប៉ុន ឬក៏នៅស្ថានទូត/ស្ថានកុងស៊ុលជប៉ុនប្រចាំប្រទេសនានាជាដើម ។

នៅសម័យសង្គ្រាមដ៏រ៉ាំរ៉ៃ ពេលណាដែលខ្ញុំមើលឃើញឬស្តាប់ឮពីការលំបាករបស់ប្រជាពលរដ្ឋកម្ពុជា ខ្ញុំតែងតែមានអារម្មណ៍ឈឺចាប់ ជាពិសេសនៅពេលខ្ញុំនឹកដល់បងប្អូនដែលធ្លាប់មានទំនាក់ទំនងយ៉ាងល្អជាមួយខ្ញុំ។ បច្ចុប្បន្ននេះ ខ្ញុំបានមកដល់ប្រទេសកម្ពុជាក្នុងតំណែងថ្មី ខ្ញុំមានសេចក្តីសប្បាយរីករាយក្នុងនាមជាមិត្តចាស់ម្នាក់របស់កម្ពុជា បានឃើញនូវស្ថានភាពជាក់ស្តែងរបស់កម្ពុជា ដែលមានស្ថេរភាពនយោបាយឡើងវិញ និងសម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ ។

ទំនាក់ទំនងជាមួយបងប្អូនកម្ពុជាកន្លងមក គឺជាទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានសម្រាប់ជីវិតរបស់ខ្ញុំ។ ដូច្នេះគោលបំណងដំបូងរបស់ខ្ញុំសម្រាប់បេសកកម្មថ្មីនេះគឺដើម្បីធ្វើយ៉ាងណាសងគុណឱ្យអស់ពីសមត្ថភាព នូវអ្វីដែលខ្ញុំបានទទួលពីបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់។

តាមរយៈឯកសារស្តីពីទំនាក់ទំនងពាណិជ្ជកម្មតាមសំពៅទេវិញទៅមកតាំងពីដើមសតវត្សទី១៧ យើងឃើញថាទំនាក់ទំនងរវាងជប៉ុននិងកម្ពុជា មានប្រវត្តិសាស្ត្ររយៈពេលច្រើនសតវត្សមកហើយ។ ខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីពង្រឹងមិត្តភាពដែលមានប្រវត្តិដ៏យូរអង្វែងមកហើយនេះ ដោយពង្រីកសហប្រតិ-

បត្តិការលើច្រើនវិស័យ និងជំរុញការយល់ដឹងអំពីគ្នាឱ្យកាន់តែស៊ីជម្រៅថែមទៀតរវាងប្រជាពលរដ្ឋនៃប្រទេសយើងទាំងពីរ ។

សូមជូនពរសូមឱ្យព្រះរាជាណាចក្រកម្ពុជាកាន់តែមានការរីកចម្រើនថែមទៀត សូមឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសុខភាពល្អ និងសុភមង្គល សូមឱ្យចំណងមិត្តភាពរវាងប្រទេសជប៉ុននិងព្រះរាជាណាចក្រកម្ពុជាមានវឌ្ឍនភាពជារៀងរហូតតទៅ ។

សូមអរគុណ ។

**កាតស៊ឹហ៊ីរ៉ូ ស៊ីណូហារ៉ា**

ឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាព

នៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា